**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣

# អូស្ត្រាលីគាំទ្រមន្ត្រីកម្ពុជាទៅទស្សនកិច្ចសិក្សាអំពីការរចនាផ្លូវនៅអូស្ត្រាលី

អូស្ត្រាលីបានគាំទ្រមន្ត្រីជាន់ខ្ពស់ពីររូបពីក្រសួងសាធារណការនិងដឹកជញ្ជូន ធ្វើដំណើរទៅកាន់ទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី កាលពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ដើម្បីទទួលយកបទពិសោធន៍ពីការអនុវត្តល្អបំផុតរបស់អូស្ត្រាលី ក្នុងការរចនាផ្លូវ។

ទស្សនកិច្ចនេះគាំទ្រដោយកម្មវិធីភាពជាដៃគូសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសអូស្ត្រាលី ហើយការធ្វើដំណើរនេះជាផ្នែកមួយនៃកិច្ចសហការរវាងទីភ្នាក់ងារដឹកជញ្ជូនអូស្ត្រាលី និងនូវែលហ្សេឡង់ ហៅថា Austroads និង ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីធ្វើបច្ចុប្បន្នភាពស្តង់ដារបច្ចេកទេសផ្លូវ និងស្ពាន នៅប្រទេសកម្ពុជា និងដើម្បីពង្រឹងសមត្ថភាពក្នុងការរចនា និងសាងសង់កម្រាលផ្លូវ។

ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា បានកោតសរសើរលើកិច្ចសហការរវាង Austroads និង ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយលើកឡើងថា "ភាពជាដៃគូរវាងអូស្ត្រាលី និងកម្ពុជា ទទួលស្គាល់ថាផ្លូវដែលត្រូវបានរចនាយ៉ាងល្អប្រកប ដោយបរិយាបន្ន និងភាពធន់ ជាឆ្អឹងខ្នងនៃកំណើនសេដ្ឋកិច្ច ដែលតភ្ជាប់សហគមន៍ ព្រមទាំងជំរុញពាណិជ្ជកម្មនិងការអភិវឌ្ឍ។ ផ្លូវដែលបានរចនាឡើងយ៉ាងល្អក៏អាចទប់ទល់នឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុបានកាន់តែល្អ»។

ឯកឧត្តមបានបន្ថែមទៀតថា៖ «ការវិនិយោគលើការរចនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងសមត្ថភាពរបស់ប្រទេសកម្ពុជា ជាមាគ៌ាមួយដើម្បីឈានទៅរកភាពរីកចម្រើន»។

ក្រោមការរៀបចំរបស់ Austroads ដែលជាទីភ្នាក់ងារដឹកជញ្ជូនរួមរបស់អូស្ត្រាលី និងនូវែលហ្សេឡង់ ឯកឧត្តម ឃិត ប៊ុណ្ណា រដ្ឋលេខាធិការ និង ឯកឧត្តម ហេង រត្នពិសិដ្ឋ អគ្គនាយក របស់ក្រសួងសាធារណការនិងដឹកជញ្ជូន បានចូលរួមក្នុងកម្មវិធីមួយចំនួន រួមទាំងបានចូលរួមក្នុងសន្និសីទអន្តរជាតិរបស់សមាគមផ្លូវថ្នល់អូស្ត្រាលី នៅថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ព្រមទាំង ដំណើរទស្សនកិច្ចនានា។

ក្រោមប្រធានបទ "ការត្រួសត្រាយផ្លូវទៅកាន់កាបូនសូន្យដោយសុវត្ថិភាព" សន្និសីទខាងលើបានផ្តោតលើការធានាឱ្យបាននូវផ្លូវដែលត្រូវសាងសង់ប្រកបដោយនិរន្តរភាព និងភាពធន់ដោយកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន បម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់ពីព្រឹត្តិការណ៍អាកាសធាតុខ្លាំង។ ប្រតិភូកម្ពុជាបានភ្ជាប់ទំនាក់ទំនងជាមួយអ្នកជំនាញផ្លូវថ្នល់មកពីជុំវិញពិភពលោក មានទាំងខាងរដ្ឋាភិបាល វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវ។

គណៈប្រតិភូក៏បានជួបជាមួយសមភាគីមកពីអាជ្ញាធរសាងសង់ឡើងវិញនៅរដ្ឋឃ្វីនលេន និងក្រសួងដឹកជញ្ជូននិងផ្លូវធំនៅរដ្ឋឃ្វីនលេន ហៅថា TMR ព្រមទាំង Austroads ។ ការពិភាក្សាផ្តោតលើរបៀបដែលរដ្ឋឃ្វីនលេន រៀបចំផែនការ និងផ្តល់អាទិភាពលើគម្រោងផ្លូវ រួមទាំងឧទាហរណ៍នានាអំពីរបៀបដែលសុវត្ថិភាព បរិយាបន្នសង្គម និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ព្រមទាំងការពិចារណាលើបម្រែបម្រួលអាកាសធាតុ ត្រូវដាក់បញ្ចូលទៅក្នុងការរចនាផ្លូវ។ កិច្ចពិភាក្សាក៏បានលើកឡើងផងដែរ ពីផែនការបញ្ជូនបុគ្គលិក ក្រសួងសាធារណការ និងដឹកជញ្ជូន ទៅបំពេញកម្មសិក្សានៅ TMR នាពេលអនាគត។

បន្ថែមពីនេះ ក៏មានការរៀបចំទស្សនកិច្ចទៅកាន់កន្លែងធ្វើតេស្តផ្លូវថ្នល់របស់ TMR នៅកោះ Bulwer និងការដ្ឋានសាងសង់កែលម្អផ្លូវ Cleveland-Redland Bay ដែលកំពុងដំណើរការ ក្នុងទីក្រុងប្រីសបេន។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au